នស/រកអ/០១១៨/០៥៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងគោរមងារព្រះរាជាគណៈ នៃគណៈមហានិកាយ នៅព្រះរាជាណាចក្រកម្ពុជា ចំនួន១២អង្គៈ

| | | | | | |
|---|---|---|---|---|---|
| ១. | ព្រះបវរវិជ្ជា | **ស៊ឹម សារ៉ាន** | ឱ្យឡើងទីជា | **ព្រះវិន័យសំវរ** | ព្រះរាជាគណៈថ្នាក់ចញា |
| ២. | ព្រះវិមលសាគរ | **ហ្វាន់ ហឿន** | ឱ្យឡើងទីជា | **ព្រះសាសនមង្គល** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៣. | ព្រះគ្រូបញ្ញាវិមល | **ទូច ថន** | ឱ្យឡើងទីជា | **ព្រះអាយុវឌ្ឍនវង្ស** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៤. | ព្រះគ្រូសារធម្មបាល | **ទេព គឿន** | ឱ្យឡើងទីជា | **ព្រះបវរវិជ្ជា** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៥- | ព្រះភិក្ខុពុទ្ធញាណោ | **ហេង ស៊ីផុង** | ឱ្យឡើងទីជា | **ព្រះរតនវិសុទ្ធ** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៦. | ព្រះគ្រូសីលបញ្ញាឧត្តម | **ទុយ តារម្យ** | ឱ្យឡើងទីជា | **ព្រះរតនលិខិត** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៧. | ព្រះភិក្ខុខេមានន្ទោ | **ឈន់ ឈឿន** | ឱ្យឡើងទីជា | **ព្រះឧត្តមវិជ្ជា** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៨. | ព្រះភិក្ខុទក្ខប្បញ្ញោ | **យុង វិត** | ឱ្យឡើងទីជា | **ព្រះបវរធម្មមុនី** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ៩. | ព្រះភិក្ខុឥន្ទប្បញ្ញោ | **គង់ សុខហាន** | ឱ្យឡើងទីជា | **ព្រះធម្មសំវរ** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ១០. | ព្រះភិក្ខុអត្ថង្គិកោ | **ម៉ែង ណេង** | ឱ្យឡើងទីជា | **ព្រះមុនីវង្សា** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ១១. | ព្រះភិក្ខុនន្ទធម្មោ | **សាញ់ រស្មី** | ឱ្យឡើងទីជា | **ព្រះលិខិតបញ្ញា** | ព្រះរាជាគណៈថ្នាក់កិត្តិយស |
| ១២. | ព្រះភិក្ខុឧត្តមវីរិយោ | **ហេង សាឌុន** | ឱ្យឡើងទីជា | **រតនកោសល** | ព្រះរាជាគណៈថ្នាក់កិត្តិយស |

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៧៩ ស.ណ

៣៧.១៨០១.០៥៣

**សំណៅចម្លងចេញពីច្បាប់ដើម**

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៨

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**